# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

<u>សេចក្តីប្រកាសពត៌មាន</u>

## ឯកអគ្គរាជទូតអញ្ជើញទស្សនកិច្ចទៅកាន់ ខេត្តព្រះវិហារនិងកំពង់ចាម

ឯកអគ្គរាជទូតអូស្ត្រាលីលោកជំទាវ **អេនជេលឡា ខកខីរ៉េន** នឹងអញ្ជើញធ្វើទស្សនកិច្ចទៅកាន់ខេត្តព្រះវិហារ និងកំពង់ចាម នៅថ្ងៃទី១១-១២ ខែកក្កដា ដើម្បីពិនិត្យមើលលទ្ធផលវិជ្ជមាននៃកម្មវិធីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់អូស្ត្រាលីចំពោះសហគមន៍កម្ពុជា។

លោកជំទាវឯកអគ្គរាជទូតខកខីរ៉េន នឹងអញ្ជើញទៅពិនិត្យមន្ទីរពេទ្យបង្អែកខេត្តព្រះវិហារ ដែលត្រូវបានកសាងឡើងក្រោមជំនួយរបស់អូស្ត្រាលី ម្ចាស់ជំនួយដទៃទៀត និងធនាគារពិភពលោក។ អូស្ត្រាលីក៏បានជួយគាំទ្រដល់ការកសាងមណ្ឌលសុខភាព សាលសម្រាលទារក និងឃ្លាំងថ្នាំពេទ្យរបស់នាយកដ្ឋានឱសថនៃមន្ទីរសុខាភិបាលខេត្ត។

លោកជំទាវនឹងពិនិត្យតំបន់ព្រំដែន និងស្តាប់នូវរបាយការណ៍សង្ខេបនៃកិច្ចខិតខំប្រឹងប្រែងរបស់កងកម្លាំងយុទ្ធពលខេមរៈភូមិន្ទកម្ពុជា ជាមួយភាគីថៃដើម្បីការធានានូវសន្តិភាព និងស្ថេរភាពក្នុងតំបន់។

នៅខេត្តកំពង់ចាម លោកជំទាវខកខីរ៉េននឹងអញ្ជើញទៅកាន់រោងចក្រផលិតទឹកស្អាត។ ក្រោមជំនួយរបស់កម្មវិធីវិនិយោគក្នុងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋាភិបាលអូស្ត្រាលី រោងចក្រនេះកំពុងផ្តល់នូវទឹកស្អាតពីបណ្តាញចែកចាយដល់ក្រុមគ្រួសារនានាក្នុងខេត្តកំពង់ចាម។

លោកជំទាវបានមានប្រសាសន៍ថា «អូស្ត្រាលីមានមោទនភាពយ៉ាងខ្លាំងក្នុងការគាំទ្រដល់ជីវភាពរបស់សហគមន៍នៅទូទាំងប្រទេសកម្ពុជា»។

នៅខេត្តព្រះវិហារ អូស្ត្រាលីកំពុងគាំទ្រដល់កម្មវិធីជាច្រើនដែលជួយដល់លទ្ធផលផ្នែកសុខភាព ការតស៊ូមតិសម្រាប់សិទ្ធិជនពិការ ការជួយដល់ការបញ្ចប់អំពើហិង្សាលើស្ត្រី និងការគាំទ្រដល់សហគមន៍កសិកម្មដើម្បីពង្រីកឱកាសសេដ្ឋកិច្ចនានា។

នៅខេត្តកំពង់ចាម អូស្ត្រាលីកំពុងធ្វើការជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលបានរងគ្រោះដោយទឹកជំនន់ ធ្វើឱ្យប្រសើរឡើងដល់ផ្លូវថ្នល់នានា គាំទ្រដល់កម្មវិធីវិទ្យុដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី និងពង្រឹងដល់លទ្ធភាពទទួលបាននូវសេវាកម្មហិរញ្ញវត្ថុនានា។

លោកជំទាវបានបន្ថែមថា «ជំនួយរបស់អូស្ត្រាលីដល់ខេត្តព្រះវិហារ និងកំពង់ចាម ជាផ្នែកមួយនៃការប្តេជ្ញាចិត្តដ៏រឹងមាំនិងយូរអង្វែងរបស់យើងក្នុងការគាំទ្រដល់ការអភិវឌ្ឍន៍របស់កម្ពុជា និងបានរឹតបន្តឹងនូវទំនាក់ទំនងទ្វេភាគីបន្ថែមទៀត»។

**ទំនាក់ទំនងពត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au

**ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧**